សូមស្វាគមន៍ មាតាបិតា និងអាណាព្យាបាល៖

យើងខ្ញុំសូមអរគុណចំពោះការចាប់ផ្ដើមឆ្នាំសិក្សាដ៏រឹងមាំ។ ក្នុងនាមជា មាតាបិតា និងអាណាព្យាបាល លោកអ្នកជាដៃគូដ៏សំខាន់ក្នុងការផ្ដល់ការអប់រំដែលមានគុណភាពដល់សិស្សានុសិស្សគ្រប់រូប នៅសាលា D. Newlin Fell ហើយចាប់ផ្ដើមជាមួយការមករៀនទាន់ពេលជារៀងរាល់ថ្ងៃរបស់សិស្សានុសិស្ស។ សូមពិនិត្យមើលឡើងវិញអំពីច្បាប់ វត្តមានអវត្តមាន និងការគេចសាលា។ ការផ្លាស់ប្ដូរទូទាំងក្រសួងសម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ សរសេរជាអក្សរខ្មៅក្រាស់។

**ការមកដល់ និងការមកយឺតពេល៖**

- សាលាចាប់ផ្ដើមបើកនៅម៉ោង ៨:៣០ ព្រឹក។ សិស្សណាម្នាក់ដែលមកដល់ក្រោយម៉ោង ៨:៣០ នឹងត្រូវកត់ទុកថាមកយឺតពេល។
- ចាប់ផ្ដើមផ្ដល់អាហារពេលព្រឹកពីម៉ោង ៨:០០ ដល ៨:២៥ ព្រឹក។ ផ្ដល់ឲ្យដោយ**មិនគិតថ្លៃ** ពីលោកអ្នក ហើយសិស្សទាំងអស់មានសិទ្ធិញ៉ាំបាន។ សិស្សានុសិស្សមិនអាចញ៉ាំអាហារពេលព្រឹកក្រោយម៉ោង ៨:២០ បានទេ។ ពួកគេត្រូវការ ៥នាទី ដើម្បីញ៉ាំ។
- សិស្សានុសិស្សដែលមិនមែននៅក្នុងតំបន់នេះ ប៉ុន្តែមករៀនដោយសារកាលៈទេសៈចាំបាច់ ដូចជា ផ្លាស់ទីលំនៅបណ្ដោះអាសន្ន រស់នៅក្នុងជម្រកបណ្ដោះអាសន្ន ទទួលការបម្រើពីក្រសួង DHS ។ល។ គេអាចផ្លាស់សិស្សនេះទៅសាលាដែលនៅក្នុងតំបន់របស់ខ្លួនវិញ បើសិនជាពួកគេឧស្សាហ៍មករៀនយឺតពេល ឬអវត្តមានជាបន្តបន្ទាប់ដែលអាចប៉ះពាល់ដល់ការសិក្សារបស់ពួកគេ។
- **ច្បាប់អំពីការមករៀនយឺតថ្មីទូទាំងក្រសួង សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ -សិស្សានុសិស្សដែលមកដល់សាលាក្រោយម៉ោង ១០ ព្រឹក ត្រូវកត់ទុកថាអវត្តមានអត់មូលហេតុ កន្លះថ្ងៃ។ អវត្តមានកន្លះថ្ងៃពីរដង ស្មើនឹងអវត្តមានពេញមួយថ្ងៃ។**

**ការចេញពីរៀនមុនម៉ោង៖**

- មិនអាចចេញមុនម៉ោងបានទេ ក្រោយម៉ោង ២:៤៥។
- យើងរៀបចំឲ្យសិស្សចេញបន្តបន្ទាប់គ្នា ប៉ុន្តែក្មេងទាំងអស់ត្រូវមានអ្នកមកទទួលឲ្យទាន់ម៉ោង ៣:០៩ រសៀល។ សាលាអាចទូរស័ព្ទទៅភ្នាក់ងារប៉ូលីសនៃទីក្រុងហ្វីឡាដែលហ្វ្យា បើសិនជាគ្មានអ្នកមកទទួលសិស្ស។ សូមទូរស័ព្ទមកសាលា បើសិនជាលោកអ្នកស្ថិតនៅក្នុងភាពអាសន្នអ្វីមួយ ហើយមិនអាចមកទទួលក្មេងទាន់ពេលនៅថ្ងៃនោះ។
- **ច្បាប់ថ្មីទូទាំងក្រសួង សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ -សិស្សានុសិស្សដែលចេញពីសាលាមុន ម៉ោង ១:០០ រសៀល ត្រូវកត់ទុកថាអវត្តមានអត់មូលហេតុកន្លះថ្ងៃ។ ត្រូវផ្ញើលិខិតជូនដំណឹង ដើម្បីឲ្យគេកត់ទុកថាជាអវត្តមានមានមូលហេតុ ប៉ុន្តែនៅតែរាប់ថាជាអវត្តកន្លះថ្ងៃ។ អវត្តមានកន្លះថ្ងៃពីរដង ស្មើនឹងអវត្តមានពេញមួយថ្ងៃ។**

**អវត្តមាន៖**

- សាលាត្រូវទទួលលិខិតជូនដំណឹងក្នុងកំលុងពេល៣ថ្ងៃ ដើម្បីឲ្យអវត្តមាននោះជាអវត្តមាន មានមូលហេតុ។

បន្តនៅទំព័រខាងក្រោយ

- សូមកត់សម្គាល់ថា ការទៅវិស្សមកាលមិនរាប់ថាជាអវត្តមាន មានមូលហេតុ ដោយក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ ដោយរដ្ឋធិនស៊ីលវេញ៉ា នោះទេ។ ដំណើរកម្សាន្តនៃការសិក្សាទាំងអស់ ត្រូវមានការយល់ព្រមជាមុនពីនាយិកា Ashe។
- សូមជ្រាបថា បញ្ហាអាកាសធាតុ និងបងប្អូនឈឺ មិនចាត់ទុកថាជាមូលហេតុនៃអវត្តមាន ដោយក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ ដោយរដ្ឋធិនស៊ីលវេញ៉ា ទេ។
- **ច្បាប់ថ្មីទូទាំងក្រសួង សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ -គេនឹងទទួលស្គាល់លិខិតជូនដំណឹងដែលសរសេរដោយដៃ សម្រាប់ពេលមានជម្ងឺតែ៩ដងដំបូងតែប៉ុណ្ណោះ។ អវត្តមានក្រោយៗទៀត ត្រូវការលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត។ យើងខ្ញុំអាចទូរស័ព្ទទៅការិយាល័យវេជ្ជបណ្ឌិត ដើម្បីបញ្ជាក់ថាគាត់បានពិនិត្យក្មេងនោះមែន។**

**ការគេចសាលា៖**

- គេនឹងបញ្ជូនសិស្សទៅតុលាការផ្នែកសិស្សគេចសាលា នៅពេលមានអវត្តមានដោយគ្មានមូលហេតុ១០ដង។
- **អវត្តមានកន្លះថ្ងៃពីរដង ស្មើនឹងអវត្តមានពេញមួយថ្ងៃ។**

ការមករៀនទាន់ពេលវេលាជារៀងរាល់ថ្ងៃ គឺជះឥទ្ធិពលដល់ ការអប់រំ និង អាកប្បកិរិយា របស់កូនលោកអ្នក។ ជាបន្ថែមទៀត សិស្សដែលមករៀនទាន់ពេលវេលាជារៀងរាល់ថ្ងៃ មានលទ្ធភាពទូលំទូលាយក្នុងការជ្រើសរើសសាលា នៅពេលជ្រើសរើសវិទ្យាល័យតាមការជ្រើសរើស។

សូមចុះហត្ថលេខាលើការសច្ចាចំពោះវត្តមានអវត្តមាន ហើយទាក់ទងមកខ្ញុំ បើសិនជាលោកអ្នកមានសំណួរអ្វី។

-B. Meyers, MA
អ្នកផ្ដល់ឱវាទនៅសាលា
អ្នកតំណាងផ្នែក វត្តមានអវត្តមាន
សាលាបឋមសិក្សា D. Newlin Fell